ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណី
លេខ ៨៤៥
ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

សាលក្រមរដ្ឋប្បវេណី
លេខ ៤៥ "យ"
ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

# តាងនាមប្រជាពលរដ្ឋខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩
លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨៤៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨
ដោយមានសមាសភាពដូចតទៅ:

<u>ចៅក្រមជំនុំជម្រះ</u>

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

<u>ក្រឡាបញ្ជី</u>

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

-ដើមចោទឈ្មោះ [redacted] សុផង់ ភេទស្រី អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្ននៅភូមិក្រោម [redacted] ឪពុកឈ្មោះ [redacted] សំ "ស" ម្ដាយឈ្មោះ [redacted] សារី "ស" ប្ដីឈ្មោះ [redacted] ម៉ៅស្រៀង "រ" មានកូន០៣នាក់ ។

ដោយមានមេធាវី [redacted] អត្តលេខ ៧៥៥, មេធាវី [redacted] អត្តលេខ [redacted] មេធាវី [redacted] អត្តលេខ ១៣៥៧ និងមេធាវី [redacted] អត្តលេខ [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ស្ថិតនៅការិយាល័យ [redacted]

-ចុងចម្លើយឈ្មោះ [redacted] ម៉ៅស្រៀង ភេទប្រុស អាយុ ៤៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] វ៉េង "រ" ម្ដាយឈ្មោះ [redacted] គឹមណាច "រ" ប្រពន្ធឈ្មោះ [redacted] សុផង់ "រ" មានកូន ០៣នាក់។

ដោយមានមេធាវី [redacted] អត្តលេខ ១០៦៣ និងមេធាវី [redacted] អត្តលេខ ១១៨៥ ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ មេធាវី នៃក្រុមហ៊ុន [redacted] មាន អាសយដ្ឋាន [redacted]

# អង្គហេតុ និង ចំណុចទទាន

១-សាលក្រមដែលទាមទារដោយភាគី:

ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:

១.១-ឱ្យឈ្មោះ [redacted] សុផង់ ឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ [redacted] ម៉ៅស្រៀង ។

១.២-ប្រគល់អំណាចមេបាលើកូនទាំង៣នាក់ ដូចតទៅៈ

-កូនទី១ ឈ្មោះ [redacted] ម៉េងលី ភេទប្រុស កើតថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០១។

-កូនទី២ ឈ្មោះ [redacted] ម៉េងឃាង ភេទប្រុស កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦។

-កូនទី៣ ឈ្មោះ [redacted] ម៉េងគីម ភេទប្រុស កើតថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១១

ឱ្យទៅឈ្មោះ [redacted] សុផង់ ជាម្តាយ។

១.៣-ទាមទារការផ្តល់អាហារកាតព្វកិច្ចដល់កូនទាំង៣នាក់ ចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក ក្នុងមួយខែ រហូតដល់កូនៗមាននីតិភាព។

១.៤-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ដូចខាងក្រោមៈ

(១). ដីទំហំ ៦៣.១៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០២៩៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

(២). ដីទំហំ ៥៤.៣២៩ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តកបន្ទាយមានជ័យ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

(៣). ដីទំហំ ៧.៧៦៣ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនទ្រព្យលេខ ០១០៧០៥០៧-០៣០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

(៤). ដីទំហំ ៥.៧៤០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤០ ម.ព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥។

(៥). ដី និងផ្ទះ ទំហំ ១៥៨,១៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៦៣/ព.អ ២០០៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨។



Scanned with CamScanner

(៦). ដីទំហំ ៨៥៤ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៥។

(៧). ដីទំហំ ១៦០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០២ ២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨។

(៨) ដីនិងផ្ទះទំហំ ៦៧,២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះលេខ ១៧២មព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។

(៩). ដីលំនៅដ្ឋានទំហំទទឹង ១០,៧៥ ម៉ែត្រ + ១០,៩ ម៉ែត្រ និងបណ្តោយ ២៤,៩ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២១៥ ម.ព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៥។

(១០). ដីលំនៅដ្ឋានទំហំ ២៣១ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៤៣ ម.ព ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។

(១១). ដីទំហំប្រហែល ១០០០០ ម៉ែត្រការ៉េ (ខាងស្តាំស្ពានព្រែកតាមាក់) មានទីតាំងស្ថិតនៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល (ចូលហ៊ុន ៥០% ជាមួយបងប្អូនថ្លៃ)។

(១២). រថយន្តដឹកឥដ្ឋចំនួន ០៦គ្រឿង៖

-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស លេខម៉ាស៊ីន D4AL216153 ផលិតឆ្នាំ ១៩៩១ ស្លាកលេខ ភ្នំពេញ ៣B-៩៤៣២ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣។

-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស លេខម៉ាស៊ីន D៤AES១០៦១៤៤ ផលិតឆ្នាំ ១៩៩៥ ស្លាកលេខ ភ្នំពេញ ៣A-០១១៩ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស លេខម៉ាស៊ីន D៤AKR0៧៧១៩១ ផលិតឆ្នាំ ១៩៩៤ ស្លាកលេខ ភ្នំពេញ ៣A-៥១៧០ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៧។



Scanned with CamScanner

-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ខៀវ ស្លាកលេខ កំពង់ចាម ៣A-១៨៣៤។

-រថយន្តម៉ាក HYUNDAI MIGHTY ចំនួន ២គ្រឿង ដែលកំពុងជួសជុល និងកែច្នៃ

(១៣). រថយន្តទេសចរណ៍ចំនួន ០១គ្រឿង ម៉ាក VIGO ពណ៌ស ស្លាកលេខ ៧២៧១។

១.៥. រួមគ្នាសងបំណុលធនាគារ អេស៊ីលីដា សរុបចំនួន ១៥០០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨។

១.៦. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

**ខ្លឹមសារនៃសាលក្រមដែលទាមទារដោយចុងចម្លើយ៖**

១. យល់ព្រមលើការទាមទាររបស់ដើមចោទ ត្រង់ចំណុចទី១ ទី២ និងទី៥ ក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៨ របស់ដើមចោទ៖

១.១.ឱ្យឈ្មោះ [redacted] សុផង់ ឈប់រស់នៅជាអនីតិសង្វាសពីឈ្មោះ [redacted] ម៉ៅស្រៀង។

១.២. ប្រគល់អំណាចមេបាលើកូនទាំង៣នាក់ គឺកូនទី១ ឈ្មោះ [redacted] ម៉េងលី ភេទប្រុស កើតថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០១, ឈ្មោះ [redacted] ម៉េងឃាង ភេទប្រុស កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ និងកូនទី៣ ឈ្មោះ [redacted] ម៉េងគីម ភេទប្រុស កើតថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០១១ ឱ្យទៅឈ្មោះ [redacted] សុផង់ ជាម្តាយ។

១.៥. រួមគ្នាសងបំណុល ធនាគារ អេស៊ីលីដា សរុបចំនួន ១៥០០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨។

២. សុំឱ្យតុលាការចេញសាលក្រមសម្រេចបែងចែកទ្រព្យសម្បត្តិជាអចលនវត្ថុខាងក្រោម ជា ពីរចំណែកស្មើគ្នាខាងក្រោម៖

២.១. ដីទំហំ ៦៣.១៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០២៩៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

២.២. ដីទំហំ ៥៤.៣២៩ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។



Scanned with CamScanner

២.៣. ដីទំហំ ៧.៧៦៣ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាគ្រែ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

២.៤. ដីទំហំ ៥.៧៤០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤០ ម.ព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥។

២.៥. ដី និងផ្ទះទំហំ ១៥៨,១៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៤៦៣/ព.អ ២០០៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨។

២.៦. ដីទំហំ ១៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០២២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨។

២.៧. ដីនិងផ្ទះ ទំហំ ៦៧,២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះលេខ ១៧២ មព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ ។

២.៨. ដីលំនៅដ្ឋានទំហំទទឹង ១០,៧៥ ម៉ែត្រ + ១០,៩ ម៉ែត្រ និងបណ្តោយ ២៤,៩ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២១៥ មព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៥។

២.៩. ដីលំនៅដ្ឋានទំហំ ២៣១ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៤៣ មព ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។

២.១០. ដី និងផ្ទះ (ប្រភេទដីឡូតិ៍) ស្ថិតនៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។

២.១១. តូបក្នុងផ្សារព្រែកអញ្ចាញចំនួន ០៣ (បី) ស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។

៣.សុំឱ្យតុលាការចេញសាលក្រមសម្រេចបែងចែកទ្រព្យសម្បត្តិជាអចលនទ្រព្យ ជាដីទំហំ ៨៥៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០០០៨៥ ចុះថ្ងៃទី



Scanned with CamScanner

០៣ ខែមិថុនា ឆ្នាំ១៩៩៥ ទៅឱ្យឈ្មោះ [redacted] គឹមហ៊ាង ភេទស្រី មានទីលំនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ចំនួន ពាក់កណ្តាល និងពាក់កណ្តាលទៀតដែលនៅសល់សុំធ្វើការបែងចែកជាមួយដើមចោទជាពីរចំណែកស្មើគ្នា។

៤. សុំឱ្យតុលាការចេញសាលក្រមសម្រេចប្រគល់ទ្រព្យសម្បត្តិជាចលនវត្ថុខាងក្រោមមកឱ្យដើមបណ្តឹងតបម្នាក់ឯងនូវ៖

៤.១. រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស លេខម៉ាស៊ីន D4AL216153 ផលិតឆ្នាំ ១៩៩១ ស្លាកលេខ ភ្នំពេញ ៣B-៩៤៣២ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣។

៤.២-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស លេខម៉ាស៊ីន D៤AES ១០៦១៤៤ ផលិតឆ្នាំ ១៩៩៥ ស្លាកលេខ ភ្នំពេញ ៣A-០១១៩ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

៤.៣-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស លេខម៉ាស៊ីន D៤AKR ០៧៧១៩១ ផលិតឆ្នាំ ១៩៩៤ ស្លាកលេខ ភ្នំពេញ ៣A-៥១៧០ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧។

៤.៤-រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ខៀវ ស្លាកលេខ កំពង់ចាម ៣A-១៨៣៤។

៤.៥-រថយន្តម៉ាក HYUNDAI MIGHTY ចំនួន ២គ្រឿង ដែលកំពុងជួសជុល និងកែច្នៃ។

៤.៦.រថយន្តម៉ាក VIGO ពណ៌ស ស្លាកលេខ ៧២៧១។

៥.សុំឱ្យតុលាការចេញសាលក្រមសម្រេចបែងចែកទ្រព្យសម្បត្តិជាចលនវត្ថុខាងក្រោមជាពីរចំណែកស្មើគ្នាដូចខាងក្រោម៖

៥.១. គ្រឿងសង្ហារឹម គ្រឿងឈើ និងសម្ភារៈផ្សេងៗ ដែលតាំងលក់ និងរក្សាទុកនៅក្នុងដេប៉ូលក់ឈើ យីហោ កេត សុផង់។

៥.២. រថយន្តម៉ាក KIA TITAN ចំណុះទម្ងន់ ១,៥ តោន ស្លាកលេខ ភ្នំពេញ ញ-៤០៦៧ ភព ២។

៥.៣. រ៉ឺម៉កមួយគ្រឿង។

៥.៤. ម៉ាស៊ីនជ្រៀកឈើ។

៦. សុំឱ្យតុលាការសម្រេចឱ្យចុងចម្លើយ អំពីការផ្តល់អាហារកាតព្វកិច្ចដល់កូនទាំង០៣តាមលទ្ធភាព។



Scanned with CamScanner

៧. សុំឱ្យតុលាការចេញសាលក្រមសម្រេចបង្គាប់ឱ្យភាគីដើមចោទ និងចុងចម្លើយរួមគ្នាសង បំណុល ចំនួន ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក របស់ម្ចាស់បំណុលឈ្មោះ [redacted] គា ភេទ ប្រុស អាយុ ៤៨ឆ្នាំ មានទីលំនៅ[redacted]

៨. សុំឱ្យប្រកាសឱ្យអនុវត្តបណ្តោះអាសន្ននៅលើចំណុចទី៣ នៃការទាមទារ។

៩. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងបណ្តឹងតប។

២-ការពន្យល់ត្រួសៗអំពីរឿងក្តី:

កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ឈ្មោះ [redacted] សុផង់ បានដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តកណ្តាល ប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ [redacted] ម៉ៅស្រៀង ភេទប្រុស អាយុ ៤៤ឆ្នាំ ដោយលើកមូលហេតុថា រស់នៅមិនចុះសម្រុងនឹងគ្នា ចេះតែរកាំរកូសនឹងគ្នាខ្លាំងទៅៗបណ្តាលឱ្យឈ្មោះ [redacted] សុផង់ និងកូនៗត្រូវរងនូវសម្ពាតទាំងផ្លូវកាយទាំងផ្លូវចិត្ត ធ្វើឱ្យប៉ះពាល់ដល់សតិអារម្មណ៍របស់កូនៗ ដែលកំពុងស្ថិតក្នុងវ័យលូតលាស់ត្រូវការសេចក្តីស្រលាញ់ និងភាពកក់ក្តៅពីឪពុកម្តាយ។ លើសពីនេះទៀត ទោះបីជារបររអាជីវកម្មរបស់ឈ្មោះ [redacted] ម៉ៅស្រៀង កាន់តែរីកចំរើន និងមានចំណូលកាន់តែកើនឡើងក៏ដោយ ក៏គាត់ពុំបានយកចិត្តទុកដាក់ផ្គត់ផ្គង់ក្នុងគ្រួសារឡើយ ដោយការចំណាយសព្វបែបយ៉ាងនៅក្នុងគ្រួសារ ទាំងការចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃ ថ្លៃម្ហូបអាហារ ថ្លៃចំណាយការសិក្សារបស់កូនៗ ថ្នាំសង្កូវឈឺស្កាត់ គឺជាបន្ទុករបស់ឈ្មោះ [redacted] សុផង់។ រីឯប្រាក់ចំណូលរបស់គាត់ គឺគាត់បានចំណាយខ្ជះខ្ជាយទៅលើការដើរលេង ផឹកស៊ី ស្រីញី និងល្បែងនៅខាងក្រៅ និងបានយកប្រាក់ចំណូលមួយផ្នែកតូចប៉ុណ្ណោះសម្រាប់ចាត់ចែងរួមគ្នាទិញអចលនវត្ថុមួយចំនួន និងបង់រំលោះសងទៅធនាគារ។ មួយរយៈក្រោយមកនេះ ឈ្មោះ [redacted] ម៉ៅស្រៀង បានគំរាមកំហែងឱ្យឈ្មោះ [redacted] សុផង់ ប្រគល់ដីពាក់កណ្តាលដែលបានទិញចុងក្រោយ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ឱ្យទៅប្អូនរបស់គាត់ ក្នុងខណៈកន្លងមកគាត់បានយកប្រាក់ក្នុងគ្រួសារជាច្រើនប្រគល់ឱ្យម្តាយ និងប្អូនរបស់គាត់ជាអ្នកទុកដាក់ ពុំដែលប្រគល់ឱ្យមកឈ្មោះ [redacted] សុផង់ មួយកាក់មួយសេនឡើយ។ ដូច្នេះ ដើមចោទ ពុំយល់ព្រមតាមការគំរាមកំហែងរបស់គាត់ឡើយ ហើយគាត់បានព្យាយាមបង្កទំនាស់ និងចង់ប្រើហិង្សាមកលើដើមចោទ ដែលជាហេតុបណ្តាលឱ្យដើមចោទពិតជាអស់មនោសញ្ចេតនានឹងគ្នា មិនអាចបន្តរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៅមុខទៀតបានឡើយ។

៣-សេចក្តីថ្លែងការណ៍របស់គូភាគី

-ដើមចោទឈ្មោះ [redacted] សុផង់ បានថ្លែងការណ៍ថា: ខ្លួនសុំរក្សាការទាមទារ ដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ទុកជាបានការដដែល។ មូលហេតុដែលខ្លួនប្តឹងសុំលែងលះព្រោះចុងចម្លើយតែងតែប្រើប្រាស់អំពើហិង្សាមកលើរូបខ្លួន រស់នៅមិនចុះសម្រុងនឹងគ្នា។ ចំពោះកូន ០៣

នាក់ សុំសិទ្ធិគ្រប់គ្រង និងអំណាចមេបាសុំអាហារកាតព្វកិច្ចចិញ្ចឹមកូន ចំនួន ២០០០ដុល្លារ ក្នុងមួយខែ។ ចំពោះទ្រព្យសម្បត្តិរួម សុំបែងចែកតាមច្បាប់។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ថ្លែងការណ៍ថាៈ ក្នុងនាមតំណាងដោយអាណត្តិឱ្យដើមចោទ សុំរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ និងសេចក្តីថ្លែងការណ៍ ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩។ ការទាមទារចំណុចទី១ ច្រានចោលការទាមទាររបស់ចុងចម្លើយ ២.១០, ២.១១, ៣, ៤, ៥, ៦, ៧, ៨ ក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨។ ទី២ សុំឱ្យដើមចោទ បានឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយតាមការព្រមព្រៀង។ ទី៣ ប្រគល់អំណាចមេបាទៅម្តាយឈ្មោះ [redacted] សុផង់ តាមការព្រមព្រៀង។ ទី៤ បង្គាប់ឱ្យចុងចម្លើយផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងបីនាក់ចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក ក្នុងមួយខែ រហូតដល់កូនៗមាននីតិភាព។ ទី៥ បែងចែកជាពីរចំណែកស្មើគ្នា នូវអចលនវត្ថុចំនួន ១១កន្លែង (ដូចមានលម្អិត នៅក្នុងសេចក្តីថ្លែងការណ៍)។ និងចលនវត្ថុរថយន្តដឹកឥដ្ឋចំនួន ០៦គ្រឿង ព្រមទាំងរថយន្តទេសចរណ៍ម៉ាក VIGO ស្លាកលេខ ៧២៧១ សុំបែងចែកជាពីរចំណែកស្មើគ្នា។ ទី៦ រួមគ្នាសងបំណុលធនាគារ អេស៊ីលីដា សរុបចំនួន ១៥ម៉ឺនដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៧ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨។ ដោយហេតុថា ទី១ អំពីការឈប់រស់នៅជាអនីតិសង្វាសៈ ដោយកូនក្តីខ្លួន និងចុងចម្លើយ អស់មនោសញ្ចេតនារួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ហើយចុងចម្លើយក៏បានព្រមព្រៀងក្នុងការឈប់រស់នៅជាអនីតិសង្វាស ដូចនេះ សុំឱ្យតុលាការសម្រេចឱ្យគូភាគីឈប់រស់នៅជាអនីតិសង្វាសតាមការព្រមព្រៀង។ គូភាគី បានព្រមព្រៀងឯកភាពប្រគល់អំណាចមេបាលើកូនទាំង០៣នាក់ ឱ្យទៅកូនក្តីខ្លួនជាម្តាយ។ ដូច្នេះ យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី សុំឱ្យតុលាការសម្រេចតាមការព្រមព្រៀង។ ទី៣ អំពីអាហារកិច្ច ដោយកូនក្តីខ្លួន និងចុងចម្លើយមានមុខរបរផ្សេងគ្នា ហើយចំណូលរបស់ភាគីចុងចម្លើយ មានប្រចាំខែប្រហែលជាមធ្យម ៣ម៉ឺនដុល្លារអាមេរិក ដូចមាននៅក្នុងបញ្ជីប្រាក់ចំណូលប្រចាំខែមីនា មេសា ឧសភា និងមិថុនា ឆ្នាំ២០១៨ ជាភស្តុតាងបញ្ជាក់។ យោងតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី និងដើម្បីឧត្តមប្រយោជន៍របស់កូនៗ សុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយផ្តល់អាហារកិច្ចចំនួន ២០០០ ដុល្លារអាមេរិក ក្នុងមួយខែ រហូតដល់កូនៗមាននីតិភាព។ អំពីទ្រព្យសម្បត្តិរួម ចំពោះទ្រព្យសម្បត្តិអចលនវត្ថុទាំង ១១កន្លែង និងចលនវត្ថុ (ឡានដឹកឥដ្ឋទាំង០៦គ្រឿង ព្រមទាំងរថយន្តម៉ាក VIGO) ជាទ្រព្យសម្បត្តិរបស់គូភាគី យោងតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី សុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើគ្នា។ ម្យ៉ាងវិញទៀត ភាគីចុងចម្លើយក៏បានទទួលស្គាល់ថា អចលនវត្ថុទាំង១១កន្លែងខាងលើ មាន០៩កន្លែង ជាទ្រព្យសម្បត្តិរួម ហើយព្រមព្រៀងសុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើគ្នា មានតែចលនវត្ថុពីរកន្លែង ដែលជាចំណុចវិវាទ គឺចលនវត្ថុទំហំ ៨៥៤ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល និងដីទំហំប្រហែល ១០០០០ម៉ែត្រការ៉េ

(ខាងស្ដាំស្ពានព្រែកតាមាក់) មានទីតាំងស្ថិតនៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ចំពោះអចលនវត្ថុវិវាទទាំងពីរនេះ គឺពិតជាទ្រព្យសម្បត្តិរួមរបស់ភាគីប្រាកដមែន។ អំពីប្រាក់បំណុលធនាគារ អេស៊ីលីដា ចំនួន ១៥ម៉ឺនដុល្លារអាមេរិក ដែលជំពាក់ គូភាគីបានឯកភាពគ្នារួមគ្នាទទួលខុសត្រូវពីរចំណែកស្មើគ្នា។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ថ្លែងការណ៍ថា: ឆ្លងកាត់នីតិវិធីត្រៀមទាំងបីលើក ខ្លួនសូមរក្សានូវសេចក្ដីថ្លែងការណ៍របស់ខ្លួន ដែលបានថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមលើកទី១ និងលើកទី២ ក៏ដូចជាតម្កល់នូវការទាមទារ និងសេចក្ដីថ្លែងការណ៍ នៅក្នុងពាក្យបណ្ដឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨។ ខ្លួនសូមបញ្ជាក់ជូនចៅក្រមថា ផ្អែកទៅលើការទាមទារ និងសេចក្ដីថ្លែងការណ៍របស់ភាគីដើមចោទ ភាគីចុងចម្លើយបានឯកភាពយល់ព្រមឈប់រស់នៅជាអនីតិសង្វាសជាមួយនឹងភាគីដើមចោទ ប្រគល់អំណាចមេបាកូនទាំងបីនាក់ឱ្យភាគីដើមចោទ និងយល់ព្រមសងបំណុល ធនាគារ អេស៊ីលីដា សរុប ១៥ម៉ឺនដុល្លារអាមេរិក រួមគ្នា។ ចំពោះអចលនវត្ថុ ដែលកូនក្ដីខ្លួន ទាមទារសុំឱ្យធ្វើការបែងចែកជាពីរចំណែកស្មើគ្នា គឺមានកំណត់ក្នុងចំណុច ២ នៃការទាមទារក្នុងពាក្យបណ្ដឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨។ ពាក់ព័ន្ធនឹងអចលនវត្ថុនេះ ខ្លួនសុំច្រានចោលការទាមទាររបស់ភាគីដើមចោទ ក្នុងការទាមទារដីទំហំប្រហែល ១០០០០ម៉ែត្រការ៉េ (ខាងស្ដាំស្ពានព្រែកតាមាក់) មានទីតាំងស្ថិតនៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ហើយពាក់ព័ន្ធនឹង ដីទំហំ ៨៥៤ ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៥ របស់នាយកដ្ឋានសុរិយោដី ខ្លួនសូមឱ្យលោកជំទាវចៅក្រម មេត្តាសម្រេចបែងចែកចំនួន ៥០ភាគរយ ទៅឱ្យឈ្មោះ [redacted] គីមហ៊ាង ភេទស្រី មានទីលំនៅ [redacted] ឯចំណែក ៥០ភាគរយទៀត សុំឱ្យចៅក្រម ធ្វើការបែងចែកជាពីរចំណែកស្មើគ្នា។ តាមរយៈអង្គហេតុទំហំ ៨៥៤ម៉ែត្រការ៉េ នេះ ភាគីដើមចោទ និងចុងចម្លើយ មិនមានលុយគ្រប់គ្រាន់ក្នុងការទិញដីនេះទេ ហេតុនេះ ទើបហៅតតិយជន ចូលហ៊ុនគ្នាជាមួយពាក់កណ្ដាលម្នាក់។ ចំពោះចលនវត្ថុ ខ្លួនសុំរក្សាការទាមទារ ដូចចំណុចទី៤ និងទី៥ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ ដដែល។ ពាក់ព័ន្ធនឹងអាហារកិច្ច សុំឱ្យលោកស្រីចៅក្រម ឱ្យគាត់បង់អាហារកាតព្វកិច្ច ឱ្យកូនទាំង០៣នាក់តាមលទ្ធភាព។ ក្នុងអំឡុងពេលមុន មានបញ្ហាអាជីវកម្ម ដើម្បីធ្វើការរកស៊ី ដើម្បីយកមកធ្វើការចិញ្ចឹមផ្គត់ផ្គង់គ្រួសារ ព្រមទាំងធ្វើការសងបំណុលរួមរបស់ធនាគារទូទាត់បញ្ចីជាមួយឈ្មោះ [redacted] គា ដែលជាម្ចាស់បំណុល និងជាម្ចាស់ឡឥដ្ឋ នៅជំពាក់ប្រាក់សរុបចំនួន ៤ម៉ឺនដុល្លារ តាមរយៈនេះ គឺភាគីចុងចម្លើយមានកិច្ចសន្យាជំពាក់ប្រាក់ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ហេតុដូច្នេះ ខ្លួនសូមសំណូមពរឱ្យភាគីដើមចោទ និងចុងចម្លើយ រួមគ្នាសងបំណុលនេះពាក់កណ្ដាលម្នាក់។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ថ្លែងការណ៍តបថា: ចំពោះអចលនវត្ថុទំហំ ៨៥៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល គឺជាទ្រព្យ

សម្បត្តិរួមរបស់គូភាគី ពុំមានចំណែករបស់ឈ្មោះ[redacted]គីមហ័ង ឡើយ ព្រោះថាកិច្ចសន្យាទិញលក់ដីនេះ គឺធ្វើឡើងតែនឹងរវាងគូភាគី និងម្ចាស់ដី ហើយការចុះបញ្ជីផ្ទេរកម្មសិទ្ធិ គឺមានតែឈ្មោះពីរនាក់ប្ដីប្រពន្ធ [redacted] ម៉ៅស្រៀង និង [redacted] សុផង់។ ភាគីចុងចម្លើយ ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ពីការចូលហ៊ុនរួមចំណែកក្នុងការខ្ចីប្រាក់ពីឈ្មោះ [redacted] គីមហ័ង ក្នុងការទិញដីនេះទេ ហើយដើម្បីបង្គ្រប់ថ្លៃទិញដី គូភាគី បានខ្ចីប្រាក់ពីធនាគារ អេស៊ីលីដា សរុបចំនួន ១៥ម៉ឺនដុល្លារអាមេរិក ដោយពុំមានឈ្មោះ[redacted]គីមហ័ង ជាកូនបំណុល ឬអ្នកធានាក្នុងការខ្ចីប្រាក់នេះឡើយ។ លើសពីនេះ ដីដែលបានទិញពីម្ចាស់ដើមឈ្មោះ [redacted] សុធារ៉ា និងប្រពន្ធ ឈ្មោះ [redacted] ណារ៉ាវី គឺមានទំហំសរុបរហូតដល់ទៅ ៩៥៨,១២ ម៉ែត្រការ៉េ ហើយដែលការវាស់វែងជាក់ស្ដែង គឺមានរហូតដល់ទៅ ១០១៤ម៉ែត្រការ៉េ ហើយដោយសាររដ្ឋបានធ្វើផ្លូវពុះដី នេះជាពីរ ទើបមួយផ្នែកមានទំហំ ៨៥៤ម៉ែត្រការ៉េ ដែលមានប័ណ្ណលេខ ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ១៩៩៥ និងផ្នែកខាងក្រោយមានទំហំ ១៦០ម៉ែត្រការ៉េ ដែលមានប័ណ្ណលេខ ០២២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨ នេះបញ្ជាក់ថា ចុងចម្លើយ និងឈ្មោះ[redacted]គីមហ័ង ដែលទាមទារថា ខ្លួនមានចំណែកក្នុងការទិញដីនេះ ប៉ុន្តែខ្លួនបែរជាទាមទារត្រឹមតែដី ៨៥៤ម៉ែត្រការ៉េ ទៅវិញ ហើយចុងចម្លើយ ក៏បានឯកភាពឱ្យបែងចែកជាពីរចំណែកនូវដី ១៦០ម៉ែត្រការ៉េ ដែលដីទាំងពីរនេះ គឺជាដីតែមួយដែលទិញពីម្ចាស់ដីដើម។ សរុបមក ការទាមទាររបស់ចុងចម្លើយដែលសុំឱ្យធ្វើការបែងចែកដីទំហំ ៨៥៤ម៉ែត្រការ៉េ ៥០ភាគរយ ឱ្យទៅប្អូនខ្លួន និង ៥០ភាគរយ ទៀត ចែកជាពីរចំណែកឱ្យភាគី មិនមានភស្តុតាងណាបញ្ជាក់ទេ។ ពាក់ព័ន្ធនឹងដី និងផ្ទះ (ប្រភេទដីឡូតិ៍) ស្ថិតនៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ គឺពុំមាននោះទេ រីឯតូបក្នុងផ្សារព្រែកអញ្ចាញ គឺមានតែពីរប៉ុណ្ណោះ ប៉ុន្តែតូបនេះ បានលក់ក្នុងតម្លៃពីរម៉ឺនដុល្លារ ដូចមាននៅក្នុងលិខិតទិញតូបក្នុងផ្សារព្រែកអញ្ចាញ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីយកប្រាក់ទៅទិញដីពីឈ្មោះ [redacted]ណារ៉ាវី ។ ចំពោះរថយន្តម៉ាក KIA TITAN ពុំមែនជាកម្មសិទ្ធិរបស់កូនក្ដីខ្លួនឡើយ រីឯរ៉ឺម៉ក និងម៉ាស៊ីនច្រៀកឈើនោះ គឺសុទ្ធតែខូចគុណភាពមិនអាចប្រើប្រាស់បាន។ អំពីបំណុលដែលភាគីចុងចម្លើយអះអាងថា បានជំពាក់ឈ្មោះ[redacted]គា ចំនួន ៤ម៉ឺនដុល្លារអាមេរិកនោះ កូនក្ដីខ្លួន ពុំទទួលស្គាល់ឡើយ ព្រោះថា កូនក្ដីខ្លួន ពុំបានទទួលប្រាក់ ឬខ្ចីប្រាក់ ឬចុះកិច្ចសន្យាខ្ចីប្រាក់ពីឈ្មោះ [redacted] គា នេះឡើយ ដោយយោងតាមមាត្រា ៩៧៥ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យដើមចោទ សុំច្រានចោលការទាមទារចំណុចនេះ។ ខ្លួនសុំច្រានចោលការទាមទាររបស់ភាគីដើមចោទ និងសុំរក្សាការទាមទារ ដូចខាងលើទាំងអស់ដដែល។

-ចុងចម្លើយឈ្មោះ [redacted] ម៉ៅស្រៀង ថ្លែងការណ៍ថា ៖ដីដែលពាក់ព័ន្ធនឹងប្អូនខ្លួននេះ គឺដំបូងឡើយ ខ្លួនកក់ពីរនាក់ប្ដីប្រពន្ធ ហើយគេទុកឱ្យ ៥ខែ បង់បន្ត បន្ទាប់មក ខ្លួនគ្មានលុយ ក៏បបួលប្អូនខ្លួនចូលហ៊ុនជាមួយគ្នា ដោយព្រមព្រៀងគ្នា ខ្លួនយកដីកន្ទុយខាងក្រោយ ហើយដីខាងមុខ ពាក់កណ្ដាលម្នាក់។ ការ

ព្រមព្រៀងនេះ គឺព្រមព្រៀងដោយផ្ទាល់មាត់ មិនមានឯកសារភស្តុតាងជាលាយលក្ខណ៍អក្សរនោះទេ។ ដីនោះពិតជាចូលលុយប្អូនខ្លួន ១៥ម៉ឺនដុល្លារ ហើយខាងខ្លួនពីរនាក់ប្តីប្រពន្ធ ចូលលុយ ១៥៣០០០ ដុល្លារ។

<u>៤-អំពីភស្តុតាង:</u>

-សៀវភៅគ្រួសារ លេខ ០៨-១៣៧៨៦ កណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៧។

-សំបុត្របញ្ជាក់កំណើតលេខ ៥៣៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ម៉េងលី។

-សំបុត្របញ្ជាក់កំណើតលេខ ៥៣៥ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ម៉េងឃាង។

-សំបុត្របញ្ជាក់កំណើតលេខ ៥៣៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ម៉េងគីម។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០២៩៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ដែលមានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ដែលមានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ២៤០ មព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ មានទីតាំងស្ថិតនៅភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល

- លិខិតធានាអះអាង លេខ ៥៨៥/លប ២០១៥ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥។

-កិច្ចសន្យា ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥។

- កំណត់ហេតុស្តីពីការចុះពិនិត្យដីធ្លី ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ៤៦៣ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨។

-គំនូសបង្ហាញទីតាំងដី ចុះថ្ងៃទី១៤ ខែមីនា ឆ្នា២០០៨។

- កិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨។

-កិច្ចសន្យាលក់ដី លេខ ៤៦៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៧។

-កិច្ចសន្យាទិញ លក់ដី និងផ្ទះ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។

- កិច្ចសន្យាទិញ លក់ដី និងផ្ទះ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨។

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៥។

-ទម្រង់លក់ផ្តាច់ លេខ ០១០ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ។

-សលាកប័ត្របំបែកក្បាលដី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០២២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី និងផ្ទះ លេខ ៦០៣ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០។



Scanned with CamScanner

-លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ២១៥ មព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

-កិច្ចសន្យាទិញលក់ដី លេខ ០២០ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥។

-កិច្ចសន្យា ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥។

-លិខិតធានាអះអាង ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥។

-កំណត់ហេតុស្តីពីការចុះពិនិត្យដីធ្លី ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ១៤៣ មព ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។

-លិខិតធានាអះអាង ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

-កិច្ចសន្យា ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

-កំណត់ហេតុ ស្តីពីការចុះពិនិត្យដីធ្លី ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

-ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ដែលមានស្លាកលេខ ភ្នំពេញ 3A-5170 ។

-ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលមានស្លាកលេខ កណ្ដាល 3A-0119។

-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានខ្នាតមធ្យម) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧។

-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតមធ្យម និងសាជីវកម្ម) ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨

-សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់មេធាវី [redacted]។

-ពាក្យបណ្ដឹង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុផង់។

-ពាក្យបណ្ដឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ម៉ៅស្រៀង។

<u>**៥-ចំណុចវិវាទៈ**</u>

១/ តើការប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទត្រឹមត្រូវតាមច្បាប់ឬទេ?

២/ ចំពោះទ្រព្យសម្បត្តិរួមៈ

២/១/ ដីទំហំ ៨៥៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខ កណ ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៥។

២/២/ ដីទំហំប្រហែល ១០០០០ ម៉ែត្រការ៉េ (ខាងស្ពានព្រែកតាមាក់) មានទីតាំងស្ថិតនៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

២/៣/ ដី និងផ្ទះ (ប្រភេទដីឡូតិ៍) ស្ថិតនៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។

២/៤/ តូប ក្នុងផ្សារព្រែកអញ្ចាញចំនួន ០៣ ស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល។



Scanned with CamScanner

២/៥/ រថយន្តដឹកឥដ្ឋចំនួន ០៦គ្រឿង៖

ក. រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3B-9432

ខ. រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3A-0119

គ. រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3A-5170

ឃ.រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ខៀវ ស្លាកលេខ កំពង់ចាម 3A-1834

ង.រថយន្តម៉ាក HYUNDAI MIGHTY ចំនួន ០២គ្រឿង ដែលកំពុងជួសជុល និងកែច្នៃ។

២/៦/ រថយន្តទេសចរណ៍ ម៉ាក VIGO ពណ៌ស ស្លាកលេខ ៧២៧១។

២/៧/ គ្រឿងសង្ហារឹម គ្រឿងឈើ និងសម្ភារៈផ្សេងៗដែលតាំងលក់ និងរក្សាទុកនៅក្នុងដេប៉ូលក់ឈើ យីហោ [redacted] សុផង់។

២/៨/ រថយន្តម៉ាក KIA TITAN ចំណុះទម្ងន់ ១,៥ តោន ស្លាកលេខ ភ្នំពេញ ញ-៤០៦៧ ភព២។

២/៩/រ៉ឺម៉កមួយគ្រឿង។

២/១០/ម៉ាស៊ីនជ្រៀកឈើ។

៣. បំណុលចំនួន ៤ម៉ឺនដុល្លារអាមេរិក របស់ម្ចាស់បំណុលឈ្មោះ [redacted] គា ភេទប្រុស អាយុ ៤៨ឆ្នាំ [redacted]។

៤. ការស្នើសុំឱ្យប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នទៅលើការទាមទារចំណុចទី៣ នៃពាក្យបណ្ដឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨។

៥. ការទាមទារអាហារកិច្ចចិញ្ចឹមកូន បីនាក់ ចំនួន ២០០០ ដុល្លាអាមេរិក ក្នុងមួយខែ រហូតដល់កូនៗមាននីតិភាព។

<u>៦.ចំណុចគ្មានវិវាទ</u>

១/ ប្រគល់អំណាចមេបាលើកូនទាំង០៣នាក់ ឱ្យទៅម្ដាយឈ្មោះ កេត សុផង់។

២/ រួមគ្នាសងបំណុលធនាគារ អេស៊ីលីដា សរុបចំនួន ១៥០០០០ ដុល្លារអាមេរិក។

៣/ឯកភាពបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ដូចខាងក្រោម៖

៣/១/ ដីទំហំ ៦៣.១៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០២៩៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

៣/២/ ដីទំហំ ៥៤.៣២៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។



Scanned with CamScanner

៣/៣/ ដីទំហំ ៧.៧៦៣ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រែ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

៣/៤/ ដីទំហំ ៥.៧៤០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤០ មព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥។

៣/៥/ ដី និងផ្ទះ ទំហំ ១៥៨,១៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៤៦៣/ព.អ ២០០៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨។

៣/៦/ ដីទំហំ ១៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ ០២២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨។

៣/៧/ ដីនិងផ្ទះទំហំ ៦៧,២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះលេខ ១៧២ មព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។

៣/៨/ ដីលំនៅដ្ឋានទំហំទទឹង ១០,៧៥ ម៉ែត្រ + ១០,៩ ម៉ែត្រ និងបណ្តោយ ២៤,៩ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២១៥ មព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

៣/៩/ ដីលំនៅដ្ឋានទំហំ ២៣១ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៤៣ មព ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។

## សំអាងហេតុ

**តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងជាឯកសារ នៅក្នុងសំណុំរឿង និងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖**

-ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នា ត្រឹមត្រូវ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ មានន័យថា គឺមិនមានអានុភាពគតិយុត្តជាប្តីប្រពន្ធស្របច្បាប់ទេ។ តុលាការ អាចសម្រេចពីការលែងលះបាន លុះត្រាតែបុរសនារីដែលជាប្តីប្រពន្ធបានរស់នៅជាមួយគ្នាស្របច្បាប់ ពោលគឺបំពេញលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលមានបញ្ញត្តិក្នុងមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ គប្បីតុលាការចេញសាលក្រមសម្រេចច្រានចោលការទាមទាររបស់ដើមចោទ តាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



Scanned with CamScanner

-ទោះបីតុលាការចេញសាលក្រមសម្រេចច្រានចោលការទាមទាររបស់ដើមចោទ ក៏ដោយ មិនមែនមានន័យថាដើមចោទ និងចុងចម្លើយ មិនអាចទៅរៀបអាពាហ៍ពិពាហ៍ថ្មីនោះទេ គឺមានន័យថាដើមចោទ និងចុងចម្លើយ អាចទៅរៀបអាពាហ៍ពិពាហ៍ថ្មីបាន ឱ្យតែបំពេញលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលមានបញ្ញត្តិក្នុងមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី។

-ដើមចោទ និងចុងចម្លើយ បានថ្លែងការណ៍ថា តាំងពីរៀបអាពាហ៍ពិពាហ៍មក ពួកខ្លួន មានកូនចំនួនបីនាក់ ទី១ឈ្មោះ [redacted] **ម៉េងលី** ភេទប្រុស កើតថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០១ ដូចមានបញ្ជាក់នៅក្នុងសំបុត្របញ្ជាក់កំណើតលេខ ៥៣៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានមេឃុំព្រែកអញ្ចាញ, កូនទី២ ឈ្មោះ [redacted] **ម៉េងឃាង** ភេទប្រុស កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ដូចមានបញ្ជាក់ក្នុងសំបុត្របញ្ជាក់កំណើតលេខ ៥៣៥ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ និងកូនទី៣ ឈ្មោះ [redacted] **ម៉េងគីម** ភេទប្រុស កើតថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ហើយដើមចោទសុំសិទ្ធិគ្រប់គ្រងកូននោះ ។ ចុងចម្លើយ ក៏បានឯកភាពប្រគល់សិទ្ធិគ្រប់គ្រងកូនឱ្យទៅដើមចោទតាមការស្នើសុំ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

-ដើមចោទ បានប្ដឹងសុំឱ្យចុងចម្លើយផ្ដល់អាហារកាតព្វកិច្ចចិញ្ចឹមកូនទាំង០៣នាក់ ចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក ក្នុងមួយខែ រហូតកូនៗមាននីតិភាព ដោយសំអាងថា ក្នុងការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធកន្លងមក ខ្លួន និងចុងចម្លើយមានរបររកស៊ីផ្សេងគ្នា ដោយដើមចោទមានរបររកស៊ីលក់ឈើ និងគុទូផ្សេងៗ ហើយដើមចោទជាអ្នកទទួលបន្ទុកចំណាយសព្វបែបយ៉ាងនៅក្នុងគ្រួសារ ទាំងការចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃ ថ្លៃម្ហូបអាហារ ថ្លៃចំណាយការសិក្សារបស់កូនៗ ថ្នាំសង្កូវ ឈើស្ពាត់ គឺជាបន្ទុករបស់ដើមចោទ រីឯចុងចម្លើយមានរបររកស៊ីលក់ឥដ្ឋមានចំណូលជាច្រើនប្រហែល ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ក្នុងមួយខែ ដូចមានក្នុងបញ្ជីប្រាក់ចំណូលប្រចាំខែមីនា មេសា ឧសភា និងមិថុនា ឆ្នាំ ២០១៨។ ប៉ុន្តែ ចុងចម្លើយ បានបដិសេធថា ខ្លួនគ្មានលទ្ធភាពតាមការទាមទាររបស់ដើមចោទឡើយ ខ្លួនសំណូមពរសុំផ្ដល់ឱ្យតាមលទ្ធភាព។ ហេតុដូច្នេះ តុលាការនឹងធ្វើការកំណត់ពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុក តាមការជាក់ស្ដែង តាមមាត្រា ១១៤០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

-ក្នុងការរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយ មានបំណុលរួម ធនាគារ អេស៊ីលីដា សរុបចំនួន ១៥០០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ដូចបញ្ជាក់ជូននៅក្នុង កិច្ចសន្យាខ្ចីប្រាក់ (ឥណទានខ្នាតមធ្យម) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ និង កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតមធ្យម និងសាជីវកម្ម) ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៨ ដែលដើមចោទ និងចុងចម្លើយ បានឯកភាពគ្នា រួមគ្នាសងបំណុលនេះ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយ ទទួលខុសត្រូវបំណុលនេះ ដោយសាមគ្គីភាព តាមមាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណី។

-អំឡុងពេលរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយ បានអះអាងថា ខ្លួនមានទ្រព្យសម្បត្តិរួម និងស្នើសុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើគ្នា ដូចខាងក្រោម៖

១/ ដីទំហំ ៦៣.១៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០២៩៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

២/ ដីទំហំ ៥៤.៣២៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

៣/ ដីទំហំ ៧.៧៦៣ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

៤/ ដីទំហំ ៥.៧៤០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤០ មព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០១៥។

៥/ ដី និងផ្ទះ ទំហំ ១៥៨,១៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៤៦៣/ព.អ ២០០៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨។

៦/ ដីទំហំ ១៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ ០២២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨។

៧/ ដីនិងផ្ទះទំហំ ៦៧,២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះលេខ ១៧២ មព ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១០។

៨/ ដីលំនៅដ្ឋានទំហំទទឹង ១០,៧៥ ម៉ែត្រ + ១០,៩ ម៉ែត្រ និងបណ្តោយ ២៤,៩ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២១៥ មព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

៩/ ដីលំនៅដ្ឋានទំហំ ២៣១ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៤៣ មព ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៦។

ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការពិភាក្សារបស់ភាគី តាមមាត្រា ៩៨០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

-ចំពោះ ដីមួយកន្លែងទំហំ ៨៥៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ ០០០០៨៥ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ១៩៩៥ ដើមចោទ បានស្នើសុំឱ្យតុលាការធ្វើការបែងចែក ដីនេះ ជាពីរចំណែកស្មើគ្នា ជាមួយចុងចម្លើយ ព្រោះវាជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធ។ ប៉ុន្តែ ចុងចម្លើយ បានស្នើសុំឱ្យតុលាការ សម្រេចបែងចែក ៥០% ទៅឱ្យឈ្មោះ [redacted] គីមហ័ង ភេទស្រី មានទីលំនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល និង ៥០%ទៀត សុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើគ្នា ជាមួយនឹងដើមចោទដោយសំអាងថា ឈ្មោះ [redacted] គីមហ័ង បានចូលហ៊ុនពាក់កណ្តាល នៅក្នុងការទិញដីនេះ ព្រោះនៅពេលនោះ ខ្លួន និងប្រពន្ធ មិនមានលុយគ្រប់គ្រាន់ទេ ប៉ុន្តែ ចុងចម្លើយ មិនឯកសារមកបញ្ជាក់ជូនតុលាការនោះទេ ហើយដើមចោទ ក៏បានបដិសេធថា ការទិញដីនេះ គ្មានការចូលហ៊ុនពីតតិយជននោះឡើយ។ តាមការពិនិត្យភស្តុតាង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កណ ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ១៩៩៥ នៅលើប័ណ្ណសំគាល់សិទ្ធិ គឺមានតែឈ្មោះ [redacted] ម៉ៅស្រៀង និងឈ្មោះ [redacted] សុផង់ ប៉ុណ្ណោះ ហើយក៏មិនមានឯកសារបន្ថែមណា ដែលបញ្ជាក់ថា មានការចូលហ៊ុន ៥០% ពីតតិយជន ឈ្មោះ [redacted] គីមហ័ង នោះឡើយ។ ហេតុដូច្នេះ គប្បីតុលាការពិចារណាសម្រេចតាមការទាមទាររបស់ដើមចោទ។

-ដើមចោទ បានស្នើសុំបែងចែកទ្រព្យសម្បត្តិរួម ដីមួយកន្លែងទំហំប្រហែល ១០០០០ម៉ែត្រ ការ៉េ (ខាងស្តាំស្ពានព្រែកតាមាក់) មានទីតាំងស្ថិតនៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល (ចូលហ៊ុន ៥០% ជាមួយប្អូនថ្លៃ) ប៉ុន្តែ ចុងចម្លើយបានច្រានចោលការទាមទារនេះ។ ដើមចោទ មិនបានដាក់ភស្តុតាងបញ្ជាក់ពីដីខាងលើនេះទេមកតុលាការដើម្បីពិនិត្យនោះទេ ហេតុដូច្នេះ តុលាការនឹងពិចារណាលើការទាមទារនេះទេ។

-ដើមចោទ បានស្នើសុំតុលាការធ្វើការបែងចែកទ្រព្យសម្បត្តិរួម នូវ រថយន្តដឹកឥដ្ឋ ០៦ គ្រឿង រួមមាន រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3B-9432, រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3A-0119, រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3A-5170, រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ខៀវ ស្លាកលេខ កំពង់ចាម 3A-1834, រថយន្តម៉ាក HYUNDAI MIGHTY ចំនួន ០២គ្រឿង ដែលកំពុងជួសជុល និងកែច្នៃ និងរថយន្តទេសចរណ៍ ចំនួនមួយគ្រឿង ម៉ាក VIGO ពណ៌ស ស្លាកលេខ ៧២៧១ ជាពីរចំណែកស្មើគ្នា ប៉ុន្តែចុងចម្លើយ បានទាមទារឱ្យតុលាការសម្រេចប្រគល់មកឱ្យខ្លួនជាចុងចម្លើយតែម្នាក់ឯង។ តុលាការយល់ឃើញ ទ្រព្យទាំងនេះ គឺកើតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយ ហេតុដូចនេះ ទ្រព្យទាំងនេះ គឺជាទ្រព្យសម្បត្តិរួម ដូច្នេះ គប្បីតុលាការ សម្រេចធ្វើការបែងចែកជាពីរចំណែកស្មើគ្នា តាមមាត្រា ៩៨០ កថាខណ្ឌទី២ ចំណុច ខ នៃក្រមរដ្ឋប្បវេណី។

-ក្រៅពីទ្រព្យសម្បត្តិដែលដើមចោទទាមទារខាងលើ ចុងចម្លើយបានស្នើសុំឱ្យតុលាការធ្វើការបែងចែកនូវទ្រព្យសម្បត្តិ ដូចខាងក្រោម ជាពីរចំណែកស្មើគ្នា៖

១) ដី និងផ្ទះ (ប្រភេទដីឡូតិ៍) ស្ថិតនៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។

២)តូបក្នុងផ្សារព្រៃកអញ្ចាញចំនួន ០៣ ស្ថិតនៅភូមិក្រោម ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។

៣)គ្រឿងសង្ហារឹម គ្រឿងឈើ និងសម្ភារៈផ្សេងៗដែលតាំងលក់ និងរក្សាទុកនៅក្នុងដេប៉ូលក់ឈើ យីហោ គេត សុផង់។

៤) រថយន្តម៉ាក KIA TITAN ចំណុះទម្ងន់ ១,៥ តោន ស្លាកលេខ ភ្នំពេញ ញ-៤០៦៧ ភព២។

៥) រ៉ឺម៉កមួយគ្រឿង។

៦) ម៉ាស៊ីនជ្រៀកឈើ។

ប៉ុន្តែ ចុងចម្លើយ មិនបានដាក់ភស្តុតាង ជូនតុលាការដើម្បីធ្វើការពិនិត្យនោះទេ ហេតុដូច្នេះ គប្បីតុលាការនឹងមិនធ្វើការពិចារណា លើការទាមទារនេះទេ។

-ចុងចម្លើយ បានស្នើសុំឱ្យតុលាការសម្រេចបង្គាប់ឱ្យភាគីដើមចោទ និងចុងចម្លើយ រួមគ្នាសងបំណុល ចំនួន ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក របស់ម្ចាស់បំណុលឈ្មោះ [redacted] គា ភេទប្រុស អាយុ ៤៨ ឆ្នាំ មានទីលំនៅ[redacted]។ ដើមចោទ បានសុំបដិសេធការទាមទារនេះ និងសុំឱ្យតុលាការសម្រេចច្រានចោលការទាមទាររបស់ចុងចម្លើយ ដោយហេតុថា ដើមចោទ ពុំទទួលស្គាល់ចំពោះបំណុលនេះឡើយ ព្រោះថា ខ្លួនពុំទទួលបានប្រាក់ពីឈ្មោះ [redacted] គា ឬខ្ចីប្រាក់ ឬចុះកិច្ចសន្យាខ្ចីប្រាក់ពីឈ្មោះ [redacted] គា នេះឡើយ។ ចុងចម្លើយ មិនបានដាក់ភស្តុតាងមកតុលាការនោះទេ ហេតុដូច្នេះ តុលាការមិនធ្វើការពិចារណាលើចំណុចនេះឡើយ។

-ចុងចម្លើយ បានស្នើសុំឱ្យតុលារការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នលើចំណុចទី៣ នៃការទាមទារ នៃពាក្យបណ្តឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨។ តុលាការយល់ឃើញថា ការទាមទារនេះ មិនមានលក្ខណៈត្រឹមត្រូវឡើយ ហេតុដូច្នេះ គប្បីតុលាការសម្រេចច្រានចោលតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ទទួលយកពាក្យបណ្តឹងតប ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ម៉ៅស្រៀង មកពិចារណាតាមច្បាប់ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី។

២-លើកចោល ចំណុចនៃពាក្យបណ្តឹងក្នុងការសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទឈ្មោះ[redacted]សុផង់ ភេទស្រី អាយុ ៤០ឆ្នាំ។

៣-ប្រគល់អំណាចមេបា ឱ្យទៅដើមចោទឈ្មោះ [redacted] សុផង់ លើកូនទាំងបីនាក់ គឺកូនទី១ ឈ្មោះ [redacted] ម៉េងលី ភេទប្រុស កើតថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០១, កូនទី២ឈ្មោះ [redacted] ម៉េងឃាង ភេទប្រុស



Scanned with CamScanner

កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ និងកូនទី៣ឈ្មោះ [redacted] ម៉េងគីម ភេទប្រុស កើតថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៦ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

ទុកសិទ្ធិ ឱ្យចុងចម្លើយ ជាឪពុកមានសិទ្ធិទៅសួរសុខទុក្ខកូនតាមពេលវេលាសមរម្យ ។

៤-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ម៉ៅស្រៀង ជាឪពុក ផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូន ដល់កូនទាំងបីនាក់ ក្នុងមួយខែ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅរៀងរាល់ថ្ងៃទី១០ នៃខែនីមួយៗ ជាទៀងទាត់។

៥-បែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា កំណត់៖ ដើមចោទឈ្មោះ [redacted] សុផង់ ទទួលបានចំណែក ៥០% និងចុងចម្លើយឈ្មោះ [redacted] ម៉ៅស្រៀង ទទួលបានចំណែក ៥០% នូវ៖

(១). ដីទំហំ ៦៣.១៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រែ ឃុំគោកកបិន ស្រុកថ្មពួកខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០២៩៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

(២). ដីទំហំ ៥៤.៣២៩ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រែ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តកបន្ទាយមានជ័យ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០៧០៥០៧-០៣០០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

(៣). ដីទំហំ ៧.៧៦៣ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិតាត្រែ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនទ្រព្យលេខ ០១០៧០៥០៧-០៣០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣។

(៤). ដីទំហំ ៥.៧៤០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤០ ម.ព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥។

(៥). ដី និងផ្ទះ ទំហំ ១៥៨,១៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៦៣/ព.អ ២០០៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨។

(៦). ដីទំហំ ៨៥៤ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០០០០៨៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៥។

(៧). ដីទំហំ ១៦០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ. ០២២៦១៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨។



Scanned with CamScanner

(៨) ដីនិងផ្ទះទំហំ ៦៧,២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះលេខ ១៧២មព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។

(៩). ដីលំនៅដ្ឋានទំហំទទឹង ១០,៧៥ ម៉ែត្រ + ១០,៩ ម៉ែត្រ និងបណ្តោយ ២៤,៩ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២១៥ ម.ព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

(១០). ដីលំនៅដ្ឋានទំហំ ២៣១ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៤៣ ម.ព ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។

៦-បែងចែកទ្រព្យសម្បត្តិរួម នូវ រថយន្តដឹកឥដ្ឋ ០៦ គ្រឿង រួមមាន រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3B-9432, រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3A-0119, រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ស ស្លាកលេខ ភ្នំពេញ 3A-5170, រថយន្តម៉ាក HYUNDAI MIGHTY ពណ៌ខៀវ ស្លាកលេខ កំពង់ចាម 3A-1834, រថយន្តម៉ាក HYUNDAI MIGHTY ចំនួន ០២គ្រឿង ដែលកំពុងជួសជុល និងកែច្នៃ និងរថយន្តទេសចរណ៍ចំនួនមួយគ្រឿង ម៉ាក VIGO ពណ៌ស ស្លាកលេខ ៧២៧១ ប្រគល់ឱ្យទៅដើមចោទ និងចុងចម្លើយ ជាពីរចំណែកស្មើគ្នា។

៧-បង្គាប់ឱ្យដើមចោទ និងចុងចម្លើយ រួមគ្នាដោយសាមគ្គីភាព សងបំណុលធនាគារ អេស៊ីលីដា សរុបចំនួន ១៥០០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។

៨-ច្រានចោលការទាមទារក្រៅពីនេះ របស់ដើមចោទ និងចុងចម្លើយ។

៩-រឹបអូសប្រាក់ពន្ធ ដែលបានបង់រួច ចូលជាថវិការរដ្ឋ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា:** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ធ្វើនៅខេត្តកណ្តាល ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]